柬埔寨国情教材丛书（二）

# 柬埔寨经济

## សេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជា

卢军　编写

សេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជា

解放军外国语学院亚非语系

2005 年 12 月

# 前言

本国情教材适用于柬埔寨语高年级阶段学习，旨在通过大量阅读掌握正确的阅读方法，养成良好的阅读习惯，提高阅读技能，用知识的系统性和实用性，来激发学生的学习兴趣，增加学员对对象国经济知识的了解，系统掌握相关词汇，以便更好地适应未来工作的需要。

由于编者水平有限，加之时间仓促，书中的不足之出，敬请各位教员和学员指出，以期改正。

编者：卢军

2005 年 12 月 18 日

# មាតិកា


មេរៀនទី ១ ខ្លីៗអំពីសេដ្ឋកិច្ច

មេរៀនទី ២ បញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍នៅប្រទេសកម្ពុជា

មេរៀនទី ៣ ចក្ខុវិស័យសេដ្ឋកិច្ចអំពីអនាគតនៃប្រទេសកម្ពុជា

មេរៀនទី ៤ គួរធ្វើការកាត់បន្ថយភាពក្រីក្រដូចម្តេច ?

មេរៀនទី ៥ ម៉ាក្រូសេដ្ឋកិច្ចនៃការកាត់បន្ថយភាពក្រីក្រនៅប្រទេសកម្ពុជា

មេរៀនទី ៦ បញ្ហាប្រឈមចំពោះការចិញ្ចឹមជីវិតនៅជនបទការសិក្សាលើ ភូមិចំនួន៩នៅកម្ពុជា

មេរៀនទី ៧ ការឆ្លងកាត់នៅព្រំដែននៅឃុំប៉ោយប៉ែត

មេរៀនទី ៨ របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# ផ្នែកទី ១

## មេរៀនទី ១

## ខ្លីៗអំពីសេដ្ឋកិច្ច



អត្ថន័យសំខាន់ ៖

ប្រទេសកម្ពុជា បានឆ្លងផុតពីសង្គ្រាមអស់រយៈពេលជាងពីរទសវត្សកន្លងមកហើយ ។ ក្រោយសង្គ្រាមត្រូវបានបញ្ចប់ រាជរដ្ឋាភិបាលបានរៀបចំបង្កើតរដ្ឋធម្មនុញ្ញមួយដែលមានចែងពីសេដ្ឋកិច្ចទីផ្សារសេរីនៅក្នុងជំពូកទី៥មាត្រា៥៦ អំពីសេដ្ឋកិច្ចបានចែងថា ព្រះរាជណាចក្រកម្ពុជាអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។ការរៀបចំ និងការប្រព្រឹត្តទៅនៃប្រពន្ធ័សេដ្ឋកិច្ចនេះ នឹងមានកំណត់ក្នុងច្បាប់" ។ ប៉ុន្តែ អ្នកដឹងទេ តើអ្វីជាសេដ្ឋកិច្ច អ្វីជាសេដ្ឋកិច្ចអភិវឌ្ឍន៍ អ្វីជាសេដ្ឋកិច្ចទីផ្សារ ? តាមរៀនមេរៀននេះយើងនឹងយល់ស្គាល់អំពីបញ្ហាទាំងអស់នេះ ។

អ្វីទៅដែលហៅថាសេដ្ឋកិច្ច ?

សេដ្ឋកិច្ច គឺជាវិទ្យាសាស្ត្រសង្គមដែលជួយយើងងាយធ្វើផែនការ ជ្រើសរើស និងបែងចែកធនធានដែលកំរដើម្បីបំពេញតំរូវការរបស់យើង រួមមានទំនិញ និងសេវា ។ វិធីសាស្ត្រសេដ្ឋកិច្ចអាចជួយយើងម្នាក់ៗនិងជាក្រុមដើម្បីសំរេចចិត្តថាអ្វី ពេលណា កន្លែងណា ពីអ្នកណា របៀបដូចម្តេច និងចំនួនប៉ុន្មានដើម្បីផលិត ។ ការសិក្សាពីសេដ្ឋកិច្ច គឺសិក្សាអំពីធនធានដែលកំរ ការជ្រើសរើស ការសំរបសំរួលការបណ្តាក់ទុនថ្លៃដើមរបស់ផលិតកម្ម ម៉ាឃីតធីងនិងផលចំណេញពីប្រសិទ្ធភាព និងការធ្វើឱ្យមានប្រាក់ចំណេញ ។

សេដ្ឋកិច្ច គឺជាវិទ្យាសាស្ត្រសង្គមដោយវាបានធ្វើការទោះទាយ និងពន្យល់ចំនុចខ្លះៗរបស់លក្ខណៈមនុស្ស ។ វាមិនមែនជាវិទ្យាសាស្ត្រពិតដូចជារូបវិទ្យា គីមី ឬវិស្វកម្មដែលធ្វើទៅតាមច្បាប់បង្កើតនោះទេ។ ទ្រឹស្តីសេដ្ឋកិច្ចវាផ្អែកទៅលើចំនួននៃការសន្មតដែលពេលខ្លះមិនអាចអនុវត្តន៍បាននៅលើពិភពលោក ។ បញ្ហានេះ គឺត្រូវបានគេពិភាក្សានៅផ្នែកក្រោយទៀត ។

សេដ្ឋកិច្ច គឺជាការណែនាំសំរាប់ធ្វើផែនការ និងធ្វើសេចក្តីសំរេចចិត្ត។ ឧទាហរណ៍ : ច្បាប់ដំបូងជាច្រើនរបស់សេដ្ឋកិច្ចបុរាណនិយាយថា បើសិនជាមនុស្ស (ម្នាក់ៗឬក្រុម)ត្រូវបានគេឱ្យធ្វើការជ្រើសរើសតាមរបៀបផ្សេងៗក្នុងការធ្វើអ្វីមួយ នោះគេនឹងជ្រើសរើសពីរបៀបដែលអាចបន្ថយថ្លៃដើមយ៉ាងតិចបំផុតដើម្បីបានផលចំណេញច្រើនបំផុត ឬម្យ៉ាងវិញទៀតធ្វើឱ្យបានផលចំណេញច្រើនបំផុតចំពោះថ្លៃដើមដែលបានប្រើប្រាស់ ។

ប៉ុន្តែក្នុងពិភពលោកជាក់ស្តែង ផែនការ និងការជ្រើសរើសគឺមិនមែនមានឥទ្ធិពលដោយសារតែថ្លៃដើម និងផលចំណេញប៉ុណ្ណោះទេ ជានិច្ចវាអាចមានឥទ្ធិពលដោយកត្តាផ្សេងៗទៀត ដូចជាដោយការយល់ខុសគ្នារបស់ស្ថានភាព ពត៌មានដែលអាចរកបាននយោបាយ ដែលទាំងនេះមានឥទ្ធិពលទៅលើសេដ្ឋកិច្ច ។

នៅពេលសិក្សាសេដ្ឋកិច្ចវាជាការល្អណាស់ ដែលត្រូវចងចាំច្បាប់សេដ្ឋកិច្ចគឺវាមិនអាចទុកចិត្តទាំង



此为试读,需要完整PDF请访问: www.ertongbook.com

ស្រុងដូចជាច្បាប់របស់វិទ្យាសាស្ត្រពិតនោះទេ ។ ជានិច្ចជាកាលយើងមិនចាំបាច់អនុវត្តន៍តាមច្បាប់របស់សេដ្ឋកិច្ច ដែលសមហេតុផលទាំងអស់នោះទេ ។ ដោយយើងមិនអាចទោះទាយឱ្យបានត្រឹមត្រូវទាំងអស់ថាអ្វីនិងកើតឡើងក្នុងសេដ្ឋកិច្ច ។ ដូចនេះវាជាការសំខាន់ណាស់ដែលយើងគួរតែដឹងអត្ថបទអំពីសេដ្ឋកិច្ចអភិវឌ្ឍន៍ ។

**អ្វីទៅដែលហៅថាសេដ្ឋកិច្ចអភិវឌ្ឍន៍ ?**

ការអភិវឌ្ឍត្រូវបានគេកំណត់ន័យយ៉ាងងាយស្រួល ដូចជារៀបចំដំណើរការដើម្បីបង្កើនជីវភាពរស់នៅរបស់មនុស្ស ។ ដំណើរការនេះវាទាក់ទងទៅនឹងកំនើនសេដ្ឋកិច្ចដើម្បីបង្កើនប្រាក់ចំណូល បង្កើនរបស់របរប្រើប្រាស់ និងផ្តល់នូវសេវាដូចជាសុខភាព និងការអប់រំ ។ ប៉ុន្តែជានិច្ចជាកាលការអភិវឌ្ឍវាទាក់ទងទៅនឹងការប្រែប្រួលក្នុងរចនាសម្ព័ន្ធចាត់តាំង ស្ថាប័នបង្កើតការងារធ្វើ ការពារបរិស្ថាន និងជួយធ្វើឱ្យមនុស្សដើម្បីសំរេចលក្ខានុពលរបស់គេ ។

សេដ្ឋកិច្ចអភិវឌ្ឍន៍វាទាក់ទងជាបឋមទៅនឹងដំណើរការដើម្បីសំរេចកំនើនសេដ្ឋកិច្ចជាតិ ហើយយើងអាចធ្វើឱ្យវាមានភាពឋិតថេរបាន បើយើងដឹងអំពីភាពប្រែប្រួលនៃរចនាសម្ព័ន្ធសង្គម និងបរិស្ថាន ។

យើងនឹងឱ្យនិយមន័យសេដ្ឋកិច្ចអភិវឌ្ឍន៍ ដូចជាការសិក្សាអំពីកំនើនសេដ្ឋកិច្ចជាតិនូវរបៀបដែលប្រទេសអាចប្រើប្រាស់ធនធានដ៏កំររបស់គេដើម្បីសំរេចសេដ្ឋកិច្ចសមស្របទិសដៅបរិស្ថាន និងសង្គម ។ សេដ្ឋកិច្ចអភិវឌ្ឍន៍ គឺការកំណត់យុទ្ធសាស្ត្រនៃការធ្វើផែនការ និងអត្ថិភាពដើម្បីគ្រប់គ្រងការផ្លាស់ប្តូរអន្តរអំពើក្នុងបច្ចេកវិទ្យាសេដ្ឋកិច្ច សង្គម នយោបាយ និងទំនាក់ទំនងបរិស្ថានដែលកើតឡើងក្នុងកំឡុងពេលដំណើរការអភិវឌ្ឍ ។

ភាពជឿជាក់របស់មនុស្សដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចអភិវឌ្ឍន៍ ។ ទស្សនៈរបស់សេដ្ឋកិច្ច

អភិវឌ្ឍន៍ និងទំនើបភាវូបនីយកម្មមានន័យថា វត្ថុខុសគ្នាសំរាប់មនុស្សខុសគ្នា អាស្រ័យទៅលើការវិនិច្ឆ័យដ៏មានភាពជឿជាក់របស់គេអំពីអ្វីដែលល្អ និងអ្វីដែលមិនល្អ ។ ជាទូទៅការរីកចំរើនរបស់យើងមានអនុភាពលើភាពរឹងប៉ឹងរបស់ក្នុងការប្រមើលមើលទៅអនាគត និងគោលដៅរបស់យើងសំរាប់ការអភិវឌ្ឍន៍ ។

ការអភិវឌ្ឍសមស្របវាអាចធ្វើបានក្នុងប្រទេសខ្លះ បើសិនជាគោលដៅរបស់ការអភិវឌ្ឍ និងការវិនិច្ឆ័យដែលមានភាពជឿជាក់ត្រូវបានគេកំណត់ច្បាស់ និងមានយោបល់រួមខ្លះក្នុងចំណោមមនុស្សទាំងនោះអំពីគោលបំណង និងភាពជឿជាក់នេះ ។ បើសិនជាភាពជឿជាក់មិនច្បាស់លាស់ ឬមានការស្មុគស្មាញខ្លាំងអំពីគម្រូវត្ថុដែលគេចង់បាន នោះនាំឱ្យការអភិវឌ្ឍសមស្របអាចកើតឡើងតិចតួច ។

ប៉ុន្តែបើភាពជឿជាក់នេះត្រូវបានគេយល់ព្រមដោយប្រទេសមួយ ឬយ៉ាងហោចណាស់ពីអ្នកធ្វើការសំរេចចិត្តរបស់ប្រទេសមួយនោះផែនការអត្ថិភាព និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាក់លាក់ត្រូវបានប្រើប្រាស់ប្រើដើម្បីលប់បំបាត់ភាពក្រីក្រ ធានាសុវត្ថិភាពស្បៀង បង្កើនចំណូលសំរាប់មនុស្សម្នាក់ បន្ថយចំណូលដែលមិនស្មើគ្នា បន្ថយភាពអត់ការងារធ្វើ បង្កើនសេវាអប់រំ និងសុខភាពក្នុងជនបទ បង្កើនការនាំចេញ និងបន្ថយការនាំចូល ការពារសម្បត្តិធម្មជាតិ...។

ដោយសារតែធនធានវាមានដែនកំណត់ ការជ្រើសរើសត្រូវបានគេធ្វើឡើង ។ យុទ្ធសាស្ត្រ សេដ្ឋកិច្ច និងការវិភាគអាចត្រូវបានគេប្រើប្រាស់ដើម្បីជួយក្នុងការជ្រើសរើសនេះ ។

**អ្វីជាសេដ្ឋកិច្ចទីផ្សារ ?**

ក្នុងវ័យជិត ៥០ឆ្នាំ លោកសាស្ត្រាចារ្យ ទេព ស្វ៉ាន នៃមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អង្គុយធ្វើការក្នុងបន្ទប់តូចល្មមដែលមានការរៀបចំយ៉ាងមានសណ្តាប់ធ្នាប់ ប្រកបដោយទឹកមុខញញឹម ក្នុងគំនិតវិភាគទៅលើសំណួរដែលក្រុមទស្សនាវដ្តីបានសួរ ។ ទោះបីបរិយាកាសក្នុងបន្ទប់មាន

សភាពអ៊ូរអរ ដោយសូរសំលេងរបស់និស្សិតនៅខាងក្រៅជជែកគ្នាបន្តិចក៏ដោយ លោកសាស្ត្រាចារ្យបានបកស្រាយពីអត្ថន័យ និងខ្លឹមសារតាមទស្សនៈរបស់លោក ផ្នែកទីផ្សារយ៉ាងស្មោះស្ម័យមួយៗទន់ភ្លន់ ជាមួយនិងឧទាហរណ៍ជាក់ស្តែងពីស្ថានភាពសេដ្ឋកិច្ចទីផ្សារ នៅប្រទេសកម្ពុជាទីផ្សារឯកជន ប្រកបដោយកាយវិការនិងភាពវៃឆ្លាតរបស់លោកក្នុងលក្ខណៈជាគ្រូ ដែលពោរពេញដោយបទពិសោធន៍ និងគរុកោសល្យអប់រំខ្ពស់។

លោកបានបញ្ជាក់ថា ទីផ្សារសេរី គេច្រើនប្រើភ្ជាប់នឹងពាក្យសេដ្ឋកិច្ចទីផ្សារសេរី ។ ពាក្យនេះនៅប្រទេសខ្មែរយើងមានប្រជាប្រិយភាពណាស់ តាំងពីបណ្តាឆ្នាំ១៩៩០ ពីព្រោះបរិបទខ្មែរងាកទៅរកទីផ្សារសេរី ។ ពាក្យថា ទីផ្សារសេរី និយាយរួមជាទស្សនទានដែលមានចរិតប្រវត្តិសាស្ត្រផ្សារភ្ជាប់ទៅរកការកើតមាននូវអ្វីដែលជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធសេដ្ឋកិច្ចមួយប្រាកដនិយម ។ មានន័យថា ជាប្រពន្ធ័សេដ្ឋកិច្ចចាក់គ្រឹះលើសេរីភាពរបស់ភ្នាក់ងារសេដ្ឋកិច្ចទាំងឡាយរួមមានគ្រួសារ សហគ្រាស ។ ទីផ្សារជាបញ្ញត្តិអរូបី ដែលស្តែងឱ្យឃើញចំណងទាក់ទងទាំងឡាយ រវាងភ្នាក់ងារសេដ្ឋកិច្ចនៅក្នុងស្ថានភាពទិញនិងលក់ ។ ឧទាហរណ៍ : គ្រួសារមួយក្នុងស្ថានភាព និងជីវភាពរបស់ខ្លួនគ្មាននរណាអាចបង្ខិតបង្ខំឱ្យទិញនូវអ្វីដែលខ្លួនមិនត្រូវការទិញឡើយ ហើយក៏មិនតំរូវឱ្យទិញផលិតផល ឬសេវារបស់អ្នកនេះ ឬអ្នកនោះដែរ នេះគឺជាសេរីភាពរបស់បុគ្គល។

ហេតុអ្វីបានជាអ្នកទិញតថ្លៃ ហើយហេតុអ្វីបានជាអ្នកលក់កាត់ថ្លៃ ។ ឯសហគ្រាសផលិតកម្មក៏ដោយអាជីវកម្មក៏ដោយបើគេចង់ផលិតអ្វីមួយ ឬគេចង់បើកហាងអ្វីមួយនៅទីណាទំហំប៉ុណ្ណា គឺជាសិទ្ធិបុគ្គល ជាម្ចាស់ ក៏ប៉ុន្តែបុគ្គលម្នាក់ៗមានភារកិច្ចរបស់ខ្លួន ពោលគឺ បើជាអាជីវករត្រូវតែផ្គត់ផ្គង់នូវអ្វីៗ ដែលស្របទៅនឹងរូបិយរបស់អ្នកប្រើប្រាស់ក៏ដូចជាត្រូវការពារ និងធានាគុណភាព និងសុវត្ថិភាពអ្នកប្រើប្រាស់ ។ រដ្ឋមិនអាចបង្ខំ ប៉ុន្តែមានការលើកទឹកចិត្ត និងជំរុញសហគ្រាសតាមគោលការណ៍ច្បាប់ទាំងឡាយដែលត្រូវបានពិភាក្សា និងអនុម័តទទួលយកដោយសមត្ថកិច្ចជាក់ស្តែង ។ បច្ចុប្បន្នទីផ្សារសេរីគឺជាមូលដ្ឋាននៃខឿនសេដ្ឋកិច្ចសង្គម ដែលមានតំលៃសំរាប់ជំរុញឱ្យសង្គមជាតិទាំងមូលចៀសផុតពីភាពក្រីក្រ ជីវភាពរស់នៅរបស់

ប្រជាពលរដ្ឋមានការប្រែប្រួល និងរីកចំរើន ។

ចំណែកសេដ្ឋកិច្ចផែនការ រាល់សកម្មភាពផលិតកម្ម និងសេវាកម្មត្រូវស្ថិតក្រោមការចាត់ចែងរបស់រដ្ឋ ឬសមូហភាព ។ អង្គភាពផលិតកម្ម និងសេវាកម្មសំខាន់ៗ មូលដ្ឋានសម្ភារៈជាមធ្យោបាយផលិតកម្មទាំងឡាយ គឺស្ថិតក្រោមរូបភាពជាកម្មសិទ្ធិសាធារណៈ(រដ្ឋឬសមូហភាព) ។ សេដ្ឋកិច្ចផែនការផ្សារភ្ជាប់ទៅនឹងរបបសេដ្ឋកិច្ច និងសង្គម បែបសង្គមនិយម ឬកុំមុយនីស្តនិយម ។ តាមទស្សនៈផ្ទាល់របស់លោកយល់ឃើញថា ផែនការនរណាក៏មានដែរ មិនថាសេដ្ឋកិច្ចផែនការ ឬសេដ្ឋកិច្ចទីផ្សារទេ ។ ម្យ៉ាងទៀត ជំរើសដ៏ប្រសើរបំផុតនៅក្នុងសេដ្ឋកិច្ចទីផ្សារ គឺភាពប្រណាំងប្រជែង ។ ឥទ្ធិពលនៃការប្រកួតប្រជែងទាំងទីផ្សារក្នុងស្រុក និងទីផ្សារទូទាំងពិភពលោក បានបង្កឱ្យមានការប្រែប្រួលយ៉ាងខ្លាំងក្លារហូតមកដល់បច្ចុប្បន្ន នៅផ្នែកឧស្សាហកម្មនិងអាជីវកម្មក្នុងបណ្តាប្រទេសទាំងអស់ ។ អ្នកគ្រប់គ្រងក្រុមហ៊ុននីមួយៗត្រូវរិះរកមធ្យោបាយដើម្បីធ្វើយ៉ាងណាឱ្យការប្រកួតប្រជែងមានលក្ខណៈយុត្តិធម៌ និងទទួលបានប្រសិទ្ធភាពកាន់តែប្រសើរឡើង ។

មិនថាជាអាជីវកម្មនៅស្រុកខ្មែរ នៅពាសពេញពិភពលោក សុទ្ធតែមានអាជីវកម្ម និងមានច្រើនប្រភេទទៅតាមទុនរបស់ម្ចាស់ទុនម្នាក់ៗដែលមាន និងភាគហ៊ុនរបស់គេ ប៉ុន្តែដោយប្រទេសខ្មែរជាប្រទេសតូច ហើយក្រីក្រ ទើបនឹងឆ្លងផុតពីសង្គ្រាម ដូចនេះប្រភេទអាជីវកម្មភាគច្រើនគឺតូច និងមធ្យម ដូចជារោងចក្រស្រាបៀរ រោងចក្រកាត់ដេរ ក្រុមហ៊ុនទូរស័ព្ទ ។ល។ ផ្នែកប្រព័ន្ធធនាគារមិនទាន់ដំណើរការឱ្យល្អនៅឡើយ ហើយម្ចាស់ក្រុមហ៊ុននីមួយៗ ភាគច្រើនសមាសភាពបុរសជាអ្នកកាន់កាប់ មិនសូវឃើញមាននារីដែលជាម្ចាស់សហគ្រាសធំៗឱ្យបានច្រើនទេ ។ មូលហេតុទាំងអស់នេះបណ្តាលមកពីនារីមិនសូវមានាការចូលរួមនៅក្នុងសង្គមច្រើនដូចបុរស អតិថិជនមិនស្គាល់ ដោយភាគរយតិចបំផុតក្នុងមុខជំនួញធំៗផ្ទុយទៅវិញ នារីភាគច្រើនមានមុខជំនួញតូចតាច ជាអ្នកលក់ដូរក្នុងហាងក្នុងទីផ្សារ និងតូបនានា ។ ប្រសិនបើយើងវិភាគឱ្យបានជិតដល់នារីគឺជាធនធានមនុស្សដ៏មានសារសំខាន់ ទោះបីនារីខ្លះដែលមានភារកិច្ចនៅលើ

ទីផ្សារ ឬសង្គមរួមមកហើយក្តី នារីនៅតែមានកាតព្វកិច្ចចាំបាច់ ម្យ៉ាងទៀតដែលបុរសមិនអាចធ្វើបាន ឬមិនចូលចិត្តធ្វើមានន័យថា ក្រៅពីការងារសង្គមចំពោះនារីដែលមានសមត្ថភាព នាងបានចូលរួមប្រឡូកក្នុងការងារ ផ្ទះសំបែង បន្ទាប់ពីធ្វើការងារខាងក្រៅ ជាអ្នកលក់ដូរជាមន្ត្រី ជាគ្រូ ដែលបុរសទូទៅត្រូវតែគោរព និងយកជាគ្រួសារគំរូ នូវចិត្តតស៊ូអំណាត់ មិនត្អូញត្អែររបស់នារី ។ ដើម្បីជំរុញ និងជួយលើកតំកើងជីវភាពនារីក្នុងវិស័យសេដ្ឋកិច្ចទីផ្សារសើរឱ្យកាន់តែមានភាពរីកចំរើនឡើង ប្រការចាំបាច់និងជាដំណោះស្រាយរួមគឺ នារីត្រូវតែបង្កលក្ខណៈបង្កើនចំណេះដឹងឱ្យបានច្រើនថែមទៀតពីលើសមត្ថភាពដែលមានស្រាប់ ងាយស្រួលប្រឡូកក្នុងសកម្មភាពផ្សេងៗ នោះនារីនឹងមានជំនឿជាក់លើខ្លួនឯង មានជំហររឹងប៉ឹងលែងភ័យខ្លាចហ៊ានផ្សងព្រេងនៅក្នុងអាជីវកម្មដូចបុរស ប៉ុន្តែលុះត្រាតែមានការគាំទ្រទាំងកំលាំងកាយចិត្ត និងភារកិច្ចផ្សេងៗពីបុរស និងពីសំណាក់គ្រួសារផងដែរ ។

លោកបានបន្តប្រសាសន៍ទៀតថា ជាធម្មតានៅក្នុងក្រុមហ៊ុន សមាគម ឬអង្គការយើងជាម្ចាស់ក្រុមហ៊ុនត្រូវផ្តល់ឱកាសឱ្យដល់បុគ្គលិក ត្រូវធ្វើការវិភាគស្វែងយល់ពីតំរូវការរបស់អតិថិជន ហើយប៉ាន់ស្មានជាមុនពីប្រភេទផលិតផលដែលអាចលក់បាន ។ ប្រការដែលល្អសំរាប់ឱ្យក្រុមហ៊ុន ឬអ្នកលក់ដូរទទួលបានជោគជ័យ គឺត្រូវទស្សន៍ទាយទុកជាមុននូវចំនួនអតិថិជនដែលអាចនឹងទិញទំនិញ សេវាកម្ម ពេលវេលាដែលគេត្រូវការទីកន្លែង តំលៃផលិតផលដែលអ្នកលក់អាចលក់បាន និងពិសេសគឺប្រព័ន្ធផ្សព្វផ្សាយដ៏ល្អដល់គ្រប់ទីកន្លែង ជាមួយនិងដៃគូប្រកួតប្រជែង អ្នកលក់ដូរដូចគ្នា និងស្វែងរកទីផ្សារឱ្យបានច្បាស់លាស់ ។

# តារាងពាក្យថ្មីនិងពាក្យសំខាន់

| | | | |
|---|---|---|---|
| ១ | ផែនការ | ន. | 计划 |
| ២ | ក្រ | ន. | 贫困，困难 |
| ៣ | វិធីសាស្ត្រ | ន. | 方法论 |
| ៤ | សម្របសម្រួល | កិ. | 改善，协调 |
| ៥ | បណ្តាក់ | កិ. | 预购，分散 |
| ៦ | ម៉ាឃីតធីង | ន. | 市场（marketing） |
| ៧ | ទាយ | កិ. | 预测，猜 |
| ៨ | វិស្វកម្ម | ន. | 工程 |
| ៩ | ទ្រឹស្ដី | ន. | 理论，学说 |
| ១០ | ផ្អែក | កិ. | 依据，依赖 |
| ១១ | សន្មត | កិ. | 约定，规定，同意 |
| ១២ | ចំណេញ | ន. | 利润，利益 |
| ១៣ | ជាក់ស្តែង | កិ.វិ. | 确实地，具体地 |
| ១៤ | ឥទ្ធិពល | ន. | 影响，威力，效力 |
| ១៥ | កត្តា | ន. | 因素 |
| ១៦ | ទោះទាយ | កិ. | 猜测 |
| ១៧ | កំណើន | ន. | 增加，增进 |
| ១៨ | រចនាសម្ព័ន្ធ | ន. | 结构，组织，体制 |
| ១៩ | សេវា | ន. | 服务，公务，职务 |
| ២០ | ជំនឿជាក់ | ន. | 信任，坚信 |
| ២១ | បឋម | គុ. | 首先的，最初的 |
| ២២ | បរិស្ថាន | ន. | 生态、环境 |
| ២៣ | សមស្រប | កិ. | 符合，一致 |
| ២៤ | អត្ថិភាព | ន. | 实在，本质，实体 |
| ២៥ | មូលដ្ឋាន | ន. | 基础 |
| ២៦ | បច្ចេកវិទ្យា | ន. | 科技 |
| ២៧ | តួនាទី | ន. | 作用 |
| ២៨ | ទំនើបភាវូបនីយកម្ម | ន. | 现代化 |
| ២៩ | វិនិច្ឆ័យ | កិ. | 识别，判断（力） |
| ៣០ | ប្រមើល | កិ. | 眺望，俯瞰，考虑 |
| ៣១ | ស្មុគស្មាញ | គុ. | 浓密的，厚密的 |
| ៣២ | កម្មវត្ថុ | ន. | 主题，宗旨 |
| ៣៣ | ជាក់លាក់ | គុ. | 清楚的，明白的 |
| ៣៤ | លុបបំបាត់ | | 消除 |
| ៣៥ | នីតិសាស្ត្រ | ន. | 法学 |
| ៣៦ | ញញឹម | កិ. | 微笑 |
| ៣៧ | សមូហភាព | ន. | 集体，集团 |
| ៣៨ | ស្នូរ | ន. | 声音，声响 |
| ៣៩ | បកស្រាយ | ន. | 解释 |
| ៤០ | ខ្លឹមសារ | ន. | 价值，内容 |
| ៤១ | ក្បោះក្បាយ | គុ. | 清楚的，流畅的 |
| ៤២ | វៃឆ្លាត | គុ. | 聪明的，智慧的 |
| ៤៣ | គរុកោសល្យ | ន. | 儿童教育，教育 |
| ៤៤ | ប្រជាប្រិយភាព | ន. | 民间性，大众化 |
| ៤៥ | បង្ខិតបង្ខំ | កិ. | 强迫，逼迫 |
| ៤៦ | ទស្សនទាន | ន. | 理解力 |



此为试读，需要完整PDF请访问：www.ertongbook.com

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤៧ | គ្រឹះ | ន. | 基础，根基 | ៤៨ | សហគ្រាស | ន. | 企业 |
| ៤៩ | អរូបី | គុ. | 抽象的，抽象性的 | ៥០ | ស្ថានភាព | ន. | 情况，形势 |
| ៥១ | ផលិតកម្ម | ន. | 生产，出产 | ៥២ | អាជីវកម្ម | ន. | 开发，经营 |
| ៥៣ | សិទ្ធិបុគ្គល | ន. | 人权 | ៥៤ | កាតព្វកិច្ច | ន. | 义务，责任 |
| ៥៥ | រូបិយ | ន. | 货币 | ៥៦ | សុវត្ថិភាព | ន. | 平安，安好 |
| ៥៧ | អង្គភាព | ន. | 身体，本质 | ៥៨ | សម្ភារៈ | ន. | 器材，物资 |
| ៥៩ | កម្មសិទ្ធិ | ន. | 所有制，所有权 | ៦០ | ស្រាបៀរ | ន. | 啤酒 |
| ៦១ | ដេរ | កិ. | 缝，缝纫 | ៦២ | រលូន | គុ. | 细腻的，小巧的 |
| ៦៣ | អតិថិជន | ន. | 顾客 | ៦៤ | តូប | ន. | 亭子，亭子间 |
| ៦៥ | សារ | ន. | 价值，意义 | ៦៦ | ប្រឡូក | កិ. | 搅和，搅拌 |
| ៦៧ | អំណត់ | ន. | 容忍，忍耐 | ៦៨ | ត្អូញត្អែរ | កិ. | 埋怨、诉苦 |
| ៦៩ | តំកើង | កិ. | 提高，兴旺，繁荣 | ៧០ | ជំហរ | ន. | 立场 |
| ៧១ | រឹងប៉ឹង | គុ. | 坚强的，牢固的 | ៧២ | ផ្សងព្រេង | កិ. | 冒险，碰运气 |
| ៧៣ | សំណាក់ | ន. | 留宿处，寄居处 | ៧៤ | ប៉ាន់ស្មាន | កិ. | 估计，猜测 |
| ៧៥ | ប្រព័ន្ធ | ន. | 体系，系统 | ៧៦ | ដៃគូ | ន. | 伙伴，对手 |
| ៧៧ | ប្រណាំងប្រជែង | កិ. | 比赛，竞争 | ៧៨ | អត់ការងារធ្វើ | កិ. | 失业 |
| ៧៩ | សេដ្ឋកិច្ចជាតិ | ន. | 国民经济 | ៨០ | ឥទ្ធិពល | ន. | 影响 |

# លំហាត់

១.ចូរតែងឃ្លានឹងពាក្យខាងក្រោមនេះ ។

ផែនការ ផ្អែក សន្មត បឋម បកស្រាយ ប៉ាន់ស្មាន ជំហរ អាជីវកម្ម

**២.ចូរបកប្រែឃ្លាខាងក្រោមនេះទៅជាភាសាចិន ។**

១.វាមិនមែនជាវិទ្យាសាស្ត្រពិតដូចជារូបវិទ្យា គីមី ឬវិស្វកម្មដែលធ្វើទៅតាមច្បាប់បង្កើតនោះទេ។ ទ្រឹស្តីសេដ្ឋកិច្ចវាផ្អែកទៅលើចំនួននៃការសន្មតដែលពេលខ្លះមិនអាចអនុវត្តន៍បាននៅលើពិភពលោក ។

______________________________________________

______________________________________________

២.ជានិច្ចវាអាចមានឥទ្ធិពលដោយកត្តាផ្សេងៗទៀត ដូចជាដោយការយល់ខុសគ្នារបស់ស្ថានភាព ពតិមានដែលអាចរកបាននយោបាយ ដែលទាំងនេះមានឥទ្ធិពលទៅលើសេដ្ឋកិច្ច ។

______________________________________________

______________________________________________

៣.ប៉ុន្តែជានិច្ចជាកាលការអភិវឌ្ឍវាទាក់ទងទៅនឹងការប្រែប្រួល ក្នុងរចនាសម្ព័ន្ធចាត់តាំង ស្ថាប័នបង្កើតការងារធ្វើ ការពារបរិស្ថាន និងជួយធ្វើឱ្យមនុស្ស ដើម្បីសំរេចសក្តានុពលរបស់គេ ។

______________________________________________

______________________________________________

៤.ដោយសារតែធនធានវាមានដែនកំណត់ ការជ្រើសរើសត្រូវបានគេធ្វើឡើង ។ យុទ្ធសាស្ត្រ សេដ្ឋកិច្ច និងការវិភាគអាចត្រូវបានគេប្រើប្រាស់ដើម្បីជួយក្នុងការជ្រើសរើសនេះ ។

______________________________________________

______________________________________________

៥.ឥទ្ធិពលនៃការប្រកួតប្រជែងទាំងទីផ្សារក្នុងស្រុក និងទីផ្សារទូទាំងពិភពលោក បានបង្កឱ្យមានការប្រែប្រួល យ៉ាងខ្លាំងក្លារហូតមកដល់បច្ចុប្បន្ន នៅផ្នែកឧស្សាហកម្មនិងអាជីវកម្មក្នុងបណ្ដាប្រទេសទាំងអស់ ។

---

---

## ៣.ចូរបំពេញចន្លោះនឹងពាក្យខាងក្រោមនេះ ។

| | | | | | | | |
|---|---|---|---|---|---|---|---|
| សមស្រប | ផែនការ | ប្រកាន់ | ដំណើរការ | គោលការណ៍ | ប្រកួតប្រជែង | យ៉ាងណា | ជឿនលឿន |

សេដ្ឋកិច្ចទីផ្សារសេរីមានន័យថា ផ្សារជាអ្នកកំណត់តំលៃរវាងអ្នកលក់ និងអ្នកទិញ។ ________ របស់ទីផ្សារបានកំណត់______ ដើម្បីឱ្យទីផ្សារមានដំណើរការបានល្អ និងមានលក្ខណៈ____ រីឯតួនាទីរបស់រាជរដ្ឋាភិបាលវិញ គឺជួយសំរួលដល់ទីផ្សារក្នុងការ________ ឱ្យមានតម្លាភាពតែប៉ុណ្ណោះ។ ទីផ្សារចែកចេញជាពីរប្រភេទគឺ : ទីផ្សារសេរី និងទីផ្សារ______ ។ ចំពោះទីផ្សារសេរី គេសំដៅលើប្រទេសប្លុកសេរី ដែលមានទីផ្សារីកលូតលាស់ និង _______ រីឯប្រជាពលរដ្ឋរបស់គេ ក៏មានជីវភាពធូរធារជាង. ប្រជាពលរដ្ឋដែលរស់នៅក្នុងប្រទេស______យកទីផ្សារផែនការ ដែលជាប្រទេសក្នុងប្លុកកុំមុយនីស្ត ហើយទីផ្សាររបស់គេ ________ទៅតាមផែនការរបស់ប្រទេសជាអ្នកកំណត់។

## ៤.ចូរពិចារណា ហើយឆ្លើយសំនួរខាងក្រោមនេះ ។

១.តាមការរៀនសូត្រ តើអ្នកយល់ស្គាល់ថា អ្វីជាសេដ្ឋកិច្ច ?

២.ចូរអ្នកឧទ្ទេសនាមអំពីការរស់នៅមានពាក់ព័ន្ធនឹងសេដ្ឋកិច្ចរបស់ខ្លួនឯង ។

៣.ចូរអ្នកប្រៀបធៀបចំណុចខុសគ្នារវាងសេដ្ឋកិច្ចទីផ្សារនិងសេដ្ឋកិច្ចផែនការ ។

៤.ចូរអានអត្ថបទសំរាប់អាន ហើយបកប្រែជាភាសាចិន ។

## អត្ថបទសំរាប់អាន

# ប្រទេសកម្ពុជានិងសេដ្ឋកិច្ចទីផ្សារសេរី

ប្រទេសកម្ពុជា បានឆ្លងផុតពីសង្គ្រាមអស់រយៈពេលជាងពីរទសវត្សកន្លងមកហើយ ។ ក្រោយសង្គ្រាមត្រូវបានបញ្ចប់ រាជរដ្ឋាភិបាលបានរៀបចំបង្កើតរដ្ឋធម្មនុញ្ញមួយដែលមានចែងពីសេដ្ឋកិច្ចទីផ្សារសេរី នៅក្នុងជំពូកទី៥ មាត្រា៥៦ អំពីសេដ្ឋកិច្ចបានចែងថា៎ ព្រះរាជាណាចក្រកម្ពុជាអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃប្រពន្ធ័សេដ្ឋកិច្ចនេះ នឹងមានកំណត់ក្នុងច្បាប់ " ។ នេះគឺជាប្រសាសន៍របស់ឯកឧត្តម ងី តាយី អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការសិក្សាស្រាវជ្រាវ ស្តង់ដាគណនេយ្យអន្តរជាតិ ។

សេដ្ឋកិច្ចទីផ្សារសេរីមានន័យថា ផ្សារជាអ្នកកំណត់តំលៃរវាងអ្នកលក់ និងអ្នកទិញ។គោលការណ៍របស់ទីផ្សារបានកំណត់យ៉ាងណា ដើម្បីឱ្យទីផ្សារមានដំណើរការបានល្អ និងមានលក្ខណៈសមស្រប រីឯតួនាទីរបស់រាជរដ្ឋាភិបាលវិញ គឺជួយសំរួលដល់ទីផ្សារក្នុងការប្រកួតប្រជែង ឱ្យមានតម្លាភាពតែប៉ុណ្ណោះ។ ទីផ្សារចែកចេញជាពីរប្រភេទគឺ : ទីផ្សារសេរី និងទីផ្សារផែនការ ។ ចំពោះទីផ្សារសេរី គេសំដៅលើប្រទេសប្លុកសេរី ដែលមានទីផ្សារីកលូតលាស់ និងជឿនលឿន រីឯប្រជាពលរដ្ឋរបស់គេ ក៏មានជីវភាពធូរធារជាងប្រជាពលរដ្ឋដែលរស់នៅក្នុងប្រទេសប្រកាន់យកទីផ្សារផែនការ ដែលជាប្រទេសក្នុងប្លុកកុំម្មុយនីស្ត ហើយទីផ្សាររបស់គេដំណើរការទៅតាមផែនការរបស់ប្រទេសជាអ្នកកំណត់។

ប្រទេសទាំងនោះភាគច្រើនប្រទេសនិយមផលិតគ្រឿងសញ្ញុធ ជាជាងការស្វែងរកទីផ្សារជូនប្រជាពលរដ្ឋដែលជាហេតុធ្វើឱ្យប្រជាពលរដ្ឋជួបប្រទះនូវភាពក្រីក្រ និងគ្មានការងារធ្វើ ។ ទីផ្សារសេរីនៅលើពិភពលោក បានចងក្រងជាសហគមន៍ ឬបង្កើតជាអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីជួយសំរួល និងដោះស្រាយនៅពេលដែលសមាជិករបស់គេជួបប្រទះនូវបញ្ហាសេដ្ឋកិច្ចទីផ្សារនៅលើពិភពលោក ។ ដោយឡែកប្រទេសកម្ពុជាយើងដែលទើបនឹងបានបញ្ចប់សង្គ្រាម មិនទាន់អាចមានលទ្ធភាព ចូលរួមជាសមាជិករបស់

អង្គការពាណិជ្ជកម្មពិភពលោក (WTO)ផ្នែកសេដ្ឋកិច្ចនៅឡើយទេ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏រាជរដ្ឋាភិបាលយើងកំពុងតែខិតខំរិះរកមធ្យោបាយចូលរួមក្នុងអង្គការនោះដែរព្រោះថាប្រទេសយើងមិនអាចបោះជំហានទៅរកទីផ្សារសេរីដ៏ធំមួយដោយខ្លួនឯងបានឡើយដោយសារប្រជាជនរបស់យើងមានចំនួនតិចតួច និងការរកប្រាក់ចំណូលរបស់ប្រជាជននៅមានកំរិត ។ ឯកឧត្តមបានបន្តទៀតថា ដោយយោងទៅតាមរបាយ-ការណ៍របស់ធនាគារពិភពលោក (World Bank)ដែលបានលើកឡើងថា ប្រជាជនដែលអាចរស់នៅក្នុងប្រទេសមួយ ដោយមិនទអាចរកប្រាក់ចំណូលបាន ៥០ដុល្លារក្នុងមួយឆ្នាំទេនោះ គេចាត់ទុកថា ប្រទេសនោះជាប្រទេសក្រីក្រ ។ បើយោងតាមរបាយការណ៍នេះសបញ្ជាក់ឱ្យឃើញថា លទ្ធភាពនៃការរកប្រាក់ចំណូលរបស់ប្រជាជនមិនបាន ៣០០ដុល្លារផងក្នុងមួយឆ្នាំ ដូចនេះប្រាក់ចំណូលរបស់ប្រជាជននៅមានកំរិតទាបបើប្រៀបធៀបទៅនឹងការរកប្រាក់ចំណូលរបស់ប្រជាជននៃប្រទេសជិតខាង ប្រទេសកម្ពុជាស្ថិតនៅក្នុងបន្ទាត់នៃភាពក្រីក្រ សេដ្ឋកិច្ចនៅមានកំរិតខ្សោយ ។ ចំណែកឯថវិកាចំណូលរបស់រាជរដ្ឋាភិបាលភាគច្រើន បានទទួលមកពីពន្ធគយទំនិញនាំចូលរបស់បរទេសតែប៉ុណ្ណោះ។ ប៉ុន្តែដោយប្រទេសកម្ពុជាបានចូលជាសមាជិកទី ១០ របស់អាស៊ានតាំងពីថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៩មកពន្ធគយដែលប្រទេសកម្ពុជាធ្លាប់ទទួលបាននោះត្រូវបានកាត់បន្ថយជាបណ្តើរៗ ហើយនៅឆ្នាំ២០១៣ អត្រាពន្ធគយនឹងត្រូវបានកាត់បន្ថយរហូតដល់ចំណុចទាបបំផុត ។ នៅពេលនោះប្រភពចំណូលរបស់រាជរដ្ឋាភិបាល គឺពឹងផ្អែកទៅលើការយកពន្ធក្នុងស្រុកវិញ គឺ (ពន្ធដារ) ។

នៅក្នុងសេដ្ឋកិច្ច គេពុំសូវដែលឃើញមានស្ត្រីជាថ្នាក់ដឹកនាំក្រុមហ៊ុនទេ ភាគច្រើនឃើញតែបុរសជាប្រធានក្រុមហ៊ុន ។ ចំណែកស្ត្រីវិញ ភាគច្រើនគឺជាលេខា ឬជាបុគ្គលិកសេវាកម្ម ឬជាកម្មករ ។ នេះគឺជាចំណុចមួយគួរឱ្យព្រួយបារម្ភ ព្រោះថាបើគិតពីចំនួនប្រជាជននៅក្នុងប្រទេស ឃើញថាស្ត្រីមានភាគរយច្រើនជាងបុរស ៥២%។ ក្នុងចំណោម ៥២%នៃស្ត្រីទាំងអស់ស្ត្រីមានតែ ១១% ប៉ុណ្ណោះដែលបានចូលរួមនៅក្នុងសង្គមក៏ដូចជាបានចូលរួមចំណែកនៅក្នុងសេដ្ឋកិច្ចទីផ្សារសេរីដែរ ។ មូលហេតុដែលពុំបណ្តាលឱ្យមានស្ត្រីចូលរួមនៅក្នុងផ្នែកសេដ្ឋកិច្ច ឯកឧត្តមបានលើកឡើងថា ការខ្វះសមាសភាពស្ត្រីនៅក្នុងគ្រប់វិស័យ

បណ្ដាលមកពីស្ត្រីពុំសូវមានសមត្ថភាពនិងចំណេះដឹងក្នុងការគ្រប់គ្រងក្រុមហ៊ុន ។ប្រសិនបើស្ត្រីបានចូលរួមឱ្យបានច្រើននៅក្នុងទីផ្សារសេរីនោះឃើញថា ស្ត្រីពិតជាបានទទួលនូវផលចំណេញ និងផលប្រយោជន៍ដល់គ្រួសារ និងសង្គមជាតិទាំងមូលជាក់ជាមិនខាន ។

ឯកឧត្តមបានបញ្ជាក់បន្ថែមទៀតថា ដើម្បីឱ្យភាគរយស្ត្រីចូលរួមក្នុងវិស័យសេដ្ឋកិច្ចទីផ្សារសេរីកាន់តែមានចំនួនច្រើន និងដើម្បីឱ្យប្រទេសយើងឈានទៅរកការអភិវឌ្ឍន៍មួយប្រកបដោយសមធម៌យេនឌ័រ ក្រសួងត្រូវមានកម្មវិធីរៀបចំជាវគ្គពិសេស ដើម្បីជាជំនួយដល់និស្សិតដែលមានជំនាញផ្នែកបច្ចេកទេសគ្រប់បែប មាន : សេដ្ឋកិច្ច ច្បាប់ ជាដើមដើម្បីបង្ហាត់បង្រៀនបន្ថែមទៀត ដោយប្រើរយៈពេលខ្លីក៏ដូចពេលវែង ។

គោលបំណងនៃការបង្កើតកម្មវិធីនេះឡើង គឺដើម្បីជាទុនដល់ពួកគេក្នុងការស្វែងរកការងារជាពិសេសអាចឱ្យពួកគេចេះធ្វើការងារតាមចំណេះដឹង និងចេះស្វែងរកប្រាក់ចំណូលដល់ខ្លួនឯង និងគ្រួសារក៏ដូចជាការចូលរួមចំណែកក្នុងក្រុមហ៊ុន ឬឧស្សាហកម្មអាចផ្ដល់នូវសេវាកម្ម ផលិតកម្ម និងនាំមកនូវប្រាក់ចំណេញថែមទៀត ។ ក្រុមហ៊ុន និងមានវិធានការបង់ពន្ធជូនរដ្ឋ ទៅតាមគោលការណ៍របស់រាជរដ្ឋាភិបាលរៀងរាល់ឆ្នាំ តាមតិច ឬច្រើនស្របតាមវិធានការច្បាប់ ។ ទន្ទឹមនឹងនេះ រដ្ឋទទួលបានចំណូលពន្ធពីម្ចាស់ក្រុមហ៊ុន ប្រាក់ចំណូលពន្ធសេដ្ឋកិច្ចកើនឡើង ហើយប្រទេសជាតិឈានទៅរកការអភិវឌ្ឍន៍ល្អតលាស់រីកចំរើនជីវភាពប្រជាពលរដ្ឋក៏បានធូរធារថែមមួយកំរិតទៀតជំរុញឱ្យមានការកាត់បន្ថយភាពក្រីក្រជាបណ្ដើរៗ ។

ដកស្រង់ចេញពី :

-ទស្សនាវដ្ដី វេទិកាស្ត្រី ចេញផ្សាយលេខ២៧ ឆ្នាំទី៦

ខែមិនា ឆ្នាំ២០០៣ ទំព័រ០៩_១០ :ប្រទេសកម្ពុជា និងសេដ្ឋកិច្ចទីផ្សារសេរី ។



此为试读,需要完整PDF请访问: www.ertongbook.com